

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

CIAS 10

ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

Events after the Reporting Period

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

អារម្ភកថា

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបានន្ូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទ្ូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាព នយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងន្ូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាល កម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើ បច្ចុប្បន្នកម្មជាបន្តបន្ទាប់ន្ូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធ ហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និង **ក្រុមប្រឹក្សាជាតិគណនេយ្យ** ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជា ក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិង សវនកម្មឯកជន ដើម្បីបង្កើតន្ូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញ កំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័ន បញ្ជាត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដា គណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច កម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**" ត្រូវបានបកប្រែ ទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សា ស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅ នឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានា បានន្ូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ពន្ធ៍ទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ពន្ធ៍នៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីសំយកហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ង៉ែ តាយ៉ី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

អារម្ភកថា

ꕥ

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០"**។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី "គណនេយ្យ សហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ" នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន" *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* " និង *"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍនភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ព័ន្ធ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥

រដ្ឋលេខាធិការ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

ង៉ី តាយ៉ី

១ កម្មវត្ថុនៃស្តង់ដានេះ គឺដើម្បីរៀបរាប់ពី ÷

(ក) ពេលដែលអង្គភាពមួយត្រូវកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនចំពោះព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

(ខ) ការលាតត្រដាងដែលអង្គភាពមួយ ត្រូវកំណត់ពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងអំពីព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

ស្តង់ដានេះក៏តម្រូវផងដែរថា អង្គភាពមួយមិនត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុទៅតាមគោលការណ៍និរន្តរភាពអាជីវកម្មឡើយ ប្រសិនបើព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍បញ្ជាក់ច្បាស់ថា ការសន្មត់ពីគោលការណ៍និរន្តរភាពអាជីវកម្មនេះ មិនសមស្រប ។

វិសាលភាព

២ ស្តង់ដានេះត្រូវបានអនុវត្តចំពោះការធ្វើគណនេយ្យកម្ម និងចំពោះការលាតត្រដាងបង្ហាញពីព្រឹត្តិការណ៍ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

៣ ពាក្យស័ព្ទខាងក្រោមដែលបានប្រើនៅក្នុងស្តង់ដានេះ មានអត្ថន័យជាក់លាក់ដូចខាងក្រោម ÷

ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ **គឺជាព្រឹត្តិការណ៍ទាំងឡាយណាដែលមានផលល្អ និងមិនល្អដែលកើតឡើងចន្លោះការិយបរិច្ឆេទរាយការណ៍ និងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវអនុញ្ញាតឱ្យបោះផ្សាយ។ ព្រឹត្តិការណ៍ពីរប្រភេទនេះ ត្រូវបានកំណត់ ÷**

(ក) **ព្រឹត្តិការណ៍ទាំងឡាយណា ដែលផ្តល់ភស្តុតាងបន្ថែមនៅក្នុងលក្ខខណ្ឌដែលកើតឡើង នៅចុងការិយបរិច្ឆេទរាយការណ៍** *(ព្រឹត្តិការណ៍ដែលធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍)*

(ខ) ព្រឹត្តិការណ៍ទាំងឡាយដែលមានលក្ខណៈចង្អុលបង្ហាញពីលក្ខខណ្ឌដែលបានកើតឡើង បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ *(ព្រឹត្តិការណ៍ដែលមិនធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍)* ។

៤ ដំណើរការណ៍ទាក់ទងដល់ការអនុញ្ញាត ក្នុងការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ គឺមានភាពប្រែប្រួល មិនទៀង អាស្រ័យទៅលើ អ្នកគ្រប់គ្រងអង្គភាព តម្រូវការនានានៃច្បាប់ និងនីតិវិធីតាមលំដាប់លំដោយ ក្នុងការរៀបចំ និងការបញ្ចប់របាយការណ៍ហិរញ្ញវត្ថុ ។

៥ នៅក្នុងករណីខ្លះ អង្គភាពត្រូវបានតម្រូវឱ្យ យករបាយការណ៍ហិរញ្ញវត្ថុជាក់ជូនទៅម្ចាស់ភាគហ៊ុនសុំការ អនុម័តបន្ទាប់មករបាយការណ៍នេះ ត្រូវទទួលបានការបោះផ្សាយ។ នៅក្នុងករណីនេះ របាយការណ៍ហិរញ្ញវត្ថុដែល

ទទួលបានការបោះផ្សាយ គឺនៅថ្ងៃដែលបោះផ្សាយ មិនមែនជាថ្ងៃ ដែល ម្ចាស់ភាគហ៊ុនអនុម័តនោះទេ ។

ឧទាហរណ៍ ÷

អ្នកគ្រប់គ្រងអង្គភាព បានបញ្ចប់ពង្រាងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០x១ នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២0X២។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២0X២ ក្រុមប្រឹក្សាភិបាល បានពិនិត្យ របាយការណ៍ហិរញ្ញវត្ថុ និងបានអនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍នេះ។ អង្គភាពបានជូនដំណឹងស្តីពីលទ្ធផលចំណេញដែលជ្រើសចេញពីព័ត៌មាន ហិរញ្ញវត្ថុផ្សេងទៀត នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២0 x២។ របាយការណ៍ ហិរញ្ញវត្ថុត្រូវបានជូនដល់ម្ចាស់ភាគហ៊ុន និងអ្នកផ្សេងៗទៀត នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២0 X២។ ម្ចាស់ភាគហ៊ុន បានអនុម័តរបាយការណ៍នេះ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២0X២ ហើយរបាយការណ៍ហិរញ្ញវត្ថុ ដែល បានអនុម័តរួចហើយនេះ បន្ទាប់មកត្រូវបានតម្កល់ទុកនៅស្ថាប័នច្បាប់ នៅ ថ្ងៃ ទី ១៧ ខែ ឧសភា ឆ្នាំ ២0X២។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ នៅថ្ងៃទី១៨ ខែ មីនា ឆ្នាំ២0X២ (កាលបរិច្ឆេទដែលក្រុមប្រឹក្សាភិបាលអនុញ្ញាតឱ្យបោះ ផ្សាយ) ។

៦ ក្នុងករណីខ្លះ អ្នកគ្រប់គ្រងនៃអង្គភាពមួយ ត្រូវបានតម្រូវឱ្យបោះផ្សាយ របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ទៅជូនក្រុមប្រឹក្សាត្រួតពិនិត្យមួយ (ដែល

រួមមានតែសមាសភាពនៃនាយកមិនមែនប្រតិបត្តិ) ដើម្បីសម្រេចអនុម័ត។ ក្នុងករណីដូចនេះ របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ នៅពេលដែលអ្នកគ្រប់គ្រង អនុញ្ញាតឱ្យបោះផ្សាយរបាយការណ៍នេះទៅ ជូនក្រុមប្រឹក្សាត្រួតពិនិត្យនេះ ។

ឧទាហរណ៍

នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០X២ អ្នកគ្រប់គ្រងនៃអង្គភាពមួយបាន អនុញ្ញាតឱ្យបោះផ្សាយ របាយការណ៍ហិរញ្ញវត្ថុ ទៅជូនក្រុមប្រឹក្សា ត្រួត ពិនិត្យមួយ។ ក្រុមប្រឹក្សាត្រួតពិនិត្យនេះ មានសមាសភាព មកពីនាយក មិនមែនប្រតិបត្តិតែមួយគត់ ហើយអាចរួមមាន តំណាងបុគ្គលិក និង តំណាងម្ចាស់ភាគកម្មខាងក្រៅ។ ក្រុមប្រឹក្សាត្រួតពិនិត្យ អនុម័តយល់ស្រប លើរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃ២៦ ខែមីនា ឆ្នាំ២០X២។ របាយ-ការណ៍ហិរញ្ញវត្ថុនេះ អាចផ្តល់ជូនម្ចាស់ភាគហ៊ុន និងអ្នកដទៃទៀត នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០X២។ ម្ចាស់ភាគហ៊ុនបានអនុម័តរបាយការណ៍ ហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ របស់ពួកគេ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០ X២ ហើយរបាយការណ៍ហិរញ្ញវត្ថុនេះ បន្ទាប់មកត្រូវបានផ្ញើជូន ស្ថាប័ន ច្បាប់ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០X២។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតបោះផ្សាយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០X២(ថ្ងៃដែលអ្នកគ្រប់គ្រងអនុញ្ញាតឱ្យបោះផ្សាយទៅជូនក្រុមប្រឹក្សា ត្រួតពិនិត្យ)

៧ ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ បញ្ជូលនូវរាល់ព្រឹត្តិការណ៍គិតទៅដល់ថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានទទួលអនុញ្ញាតឱ្យបោះផ្សាយ ។ ប្រសិនបើព្រឹត្តិការណ៍ទាំងនោះ កើតឡើង បន្ទាប់ពីថ្ងៃជូនដំណឹងជាសាធារណៈស្តីពីលទ្ធផលចំណេញ ឬ ព័ត៌មានហិរញ្ញវត្ថុដែលបានជ្រើសរើសផ្សេងទៀត ។

ការទទួលស្គាល់ និង ការវាស់វែង

ព្រឹត្តិការណ៍ត្រូវធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

៨ អង្គភាពមួយត្រូវធ្វើនិយ័តភាពនូវចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បី ឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ដែលត្រូវធ្វើនិយ័តភាពន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

៩ ខាងក្រោមនេះ គឺជាឧទាហរណ៍នៃព្រឹត្តិការណ៍ ដែលត្រូវធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ដែលតម្រូវឱ្យអង្គភាពមួយធ្វើនិយ័តភាពនូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ឬ ក៏តម្រូវឱ្យអង្គភាព ទទួលស្គាល់ធាតុដែលមិនបានទទួលស្គាល់ពីមុន ។

(ក) ការទូទាត់បន្ទាប់ ពីការិយបរិច្ឆេទរាយការណ៍នៃ ករណីនៅតុលាការដែលអង្គភាពមួយ មានកាតព្វកិច្ចបច្ចុប្បន្ននៅ ចុងគ្រារាយការណ៍។ អង្គភាព ធ្វើនិយ័តភាពចំពោះសំវិធានធន ដែលបានទទួលស្គាល់ពីមុន ដែលទាក់ទិននឹងករណីតុលាការនេះ ដោយអនុលោមតាម ស.គ.អ ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ឬ ទទួលស្គាល់សំវិធានធនថ្មី។ អង្គភាពមិនបង្ហាញ

បំណុលយថាហេតុពីព្រោះការទូទាត់ផ្តល់ភស្តុតាងបន្ថែមដែលនឹងត្រូវបានយកទៅពិចារណាដោយ អនុលោមតាមកថាខណ្ឌ ១៦ នៃ ស.គ.អ ៣៧។

(ខ) ការទទួលព័ត៌មាន បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍បានបង្ហាញឱ្យឃើញថា ទ្រព្យសកម្មមួយត្រូវបានថយចុះតម្លៃនាការិយបរិច្ឆេទរាយការណ៍ ឬថាទឹកប្រាក់នៃការខាតបង់ដោយសារការថយចុះតម្លៃដែលគេបានទទួលស្គាល់ ពីមុននៃទ្រព្យសកម្មនោះ ចាំបាច់ត្រូវធ្វើនិយ័តភាពឡើងវិញ។ ឧទាហរណ៍ ÷

(១) ការក្សេយធនរបស់ អតិថិជនម្នាក់ ដែលបានកើតឡើងបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ជាទូទៅ និងបញ្ជាក់ច្បាស់លាស់ពីការខាតបង់គណនីអតិថិជន ដែលមានស្រាប់ នៅចុងការិយបរិច្ឆេទរាយការណ៍ ហើយអង្គភាពត្រូវធ្វើនិយ័តភាពតម្លៃពិតគណេយ្យៃនៃគណនីអតិថិជននោះ ឡើងវិញ។ និង

(២) ការលក់សន្និធិ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍អាចផ្តល់ភស្តុតាងពីតំលៃអាចប៉ាន់ស្មានពិតនៃ សន្និធិនៅការិយបរិច្ឆេទរាយការណ៍ ។

(គ) ការកំណត់បន្ទាប់ពីការិយបរិច្ឆេទ រាយការណ៍អំពី ថ្លៃដើមទ្រព្យសកម្មដែលបានទិញ ឬ ចំណូលពី ទ្រព្យសកម្ម ដែលបានលក់នៅមុនការិយបរិច្ឆេទរាយការណ៍។

(ឃ) ការកំណត់បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ អំពីទឹកប្រាក់នៃការបែងចែកប្រាក់ចំណេញ ការបង់ប្រាក់បន្ថែម ប្រសិនបើអង្គភាពមានបំណុលតាមផ្លូវច្បាប់បច្ចុប្បន្ន ឬ បំណុលសាងសង់នៅការិយ បរិច្ឆេទរាយការណ៍ ដែលបង្កើតឱ្យមានការទូទាត់បែបនេះដែល ជាលទ្ធផលនៃព្រឹត្តិការណ៍នានាមុនកាលបរិច្ឆេទនោះ ។ (មើល ស.គ.អ. ១៩ អត្ថប្រយោជន៍និយោជិត)

(ង) ការរកឃើញការបន្លំ ឬ កំហុសដែលបង្ហាញថា របាយការណ៍ហិរញ្ញវត្ថុនេះមិនត្រឹមត្រូវ ។

ព្រឹត្តិការណ៍មិនត្រូវធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

១០ អង្គភាពមួយ មិនត្រូវធ្វើនិយ័តភាពនូវទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនរួចហើយ ដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

១១ ឧទាហរណ៍មួយនៃព្រឹត្តិការណ៍មិនត្រូវធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ គឺជាការធ្លាក់ចុះតម្លៃទីផ្សារនៃការវិនិយោគ នៅចន្លោះការិយ-បរិច្ឆេទរាយការណ៍ និងកាលរិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ ការធ្លាក់ចុះនៃតម្លៃទីផ្សារ ជាធម្មតាវាមិនទាក់ទងលក្ខខណ្ឌនៃការវិនិយោគទេ ប៉ុន្តែវាឆ្លុះបញ្ចាំងឃើញនូវកាលៈទេសៈនានាដែលវាបានកើតឡើងជាបន្តបន្ទាប់ ។ ហេតុនេះហើយ អង្គភាពមិនធ្វើ

និយ័តភាពលើទឹកប្រាក់ដែលបានទទួលស្គាល់រួចហើយ នៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុសម្រាប់ការវិនិយោគ។ ស្រដៀងគ្នានេះដែរ អង្គភាពមិនធ្វើបច្ចុប្បន្នកម្ម លើចំនួនទឹកប្រាក់ ដែលបានលាតត្រដាង សម្រាប់ការវិនិយោគនាការិយបរិច្ឆេទរាយការណ៍ ទោះបីជាអង្គភាពអាចត្រូវការផ្តល់ការលាតត្រដាងបន្ថែម តាមកថាខណ្ឌ ២១ ក៏ដោយ ។

ភាគលាភ

១២ ប្រសិនបើភាគលាភត្រូវបានប្រកាស ទៅឱ្យម្ចាស់ឧបករណ៍មូលធន (តាមនិយមន័យក្នុង ស.គ.អ. ៣២ *ឧបករណ៍ហិរញ្ញវត្ថុៈ ការបង្ហាញ*) បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ អង្គភាពមួយមិនត្រូវទទួលស្គាល់ភាគលាភនោះថាជាបំណុលការិយបរិច្ឆេទរាយការណ៍ឡើយ។

១៣ ប្រសិនបើ ភាគលាភត្រូវបានប្រកាសបន្ទាប់ការិយបរិច្ឆេទរាយការណ៍ ប៉ុន្តែមុនរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតិឱ្យចោះផ្សាយនោះ ភាគលាភមិនអាច ទទួលស្គាល់ថាជាបំណុលបានទេនៅចុងការិយបរិច្ឆេទ រាយការណ៍ ពីព្រោះវាមិនមានកាតព្វកិច្ចកើតឡើងនៅពេលនោះ ។ ភាគលាភបែបនេះត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ដោយយោងតាម ១ ។

និរន្តរភាពអាជីវកម្ម

១៤ អង្គភាពមួយ មិនត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តាមមូលដ្ឋាននិរន្តរភាពអាជីវកម្មឡើយ ប្រសិនបើ គណៈគ្រប់គ្រងកំណត់បន្ទាប់ពីការិយបរិច្ឆេទ

រាយការណ៍ថា ខ្លួនមានបំណងនឹងជំរុះចោលអង្គភាព ឬ បញ្ឈប់រកស៊ី ឬ ថាអង្គភាពពុំមានជម្រើសជាក់លាក់ណាផ្សេងក្រៅពីធ្វើដូច្នេះឡើយ។

១៥ ភាពស្រុតចុះក្នុងលទ្ធផលពីប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍អាចចង្អុលឱ្យឃើញថា ភាពចាំបាច់មួយ ដើម្បីយកមកពិចារណាថា តើការសន្មត់ពីនិរន្តរភាពអាជីវកម្ម នៅតែសមស្របឬយ៉ាងណា។ ប្រសិនបើ ការសន្មត់ពីនិរន្តរភាពលែងសមស្របតទៅទៀត នោះឥទ្ធិពលវាមានលក្ខណៈរាលដាលពេកដែល ស្តង់ដានេះតម្រូវឱ្យមានការផ្លាស់ប្តូរមូលដ្ឋានដ៏សំខាន់នៅក្នុងមូលដ្ឋានគណនេយ្យ ជាជាងធ្វើនិយ័តភាពលើ ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ពីមុនតាមមូលដ្ឋានគណនេយ្យដើម ។

១៦ ស.គ.អ ១ តម្រូវឱ្យមានការលាតត្រដាងបង្ហាញជាក់លាក់ ប្រសិនបើ ÷

(ក) របាយការណ៍ហិរញ្ញវត្ថុមិនត្រូវបានរៀបចំតាមមូលដ្ឋាននិរន្តរភាពអាជីវកម្ម ឬ

(ខ) គណៈគ្រប់គ្រងដឹងពីភាពមិនប្រាកដប្រជាជាសារវ័ន្ត ដែលទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌ ដែលអាចធ្វើឱ្យមានការសង្ស័យខ្លាំងទៅលើលទ្ធភាពរបស់អង្គភាពក្នុងការបន្តសកម្មភាពអាជីវកម្មជានិរន្តរភាពអាជីវកម្ម។ ព្រឹត្តិការណ៍ ឬ លក្ខខណ្ឌទាំងនោះដែលការ លាតត្រដាងព័ត៌មានតម្រូវឱ្យមានអាចកើតឡើងបន្ទាប់ពីការិយ- បរិច្ឆេទរាយការណ៍ ។

ការលាតត្រដាងព័ត៌មាន

កាលបរិច្ឆេទអនុញ្ញាតបោះផ្សាយ

១៧ អង្គភាពមួយ ត្រូវលាតត្រដាង ពីកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានគេអនុញ្ញាត ឱ្យបោះផ្សាយ និងបញ្ជាក់ពីអ្នកដែលផ្តល់ការអនុញ្ញាត នោះ។ ប្រសិនបើម្ចាស់អង្គភាព ឬ អ្នកផ្សេងទៀតមានសិទ្ធិអំណាចធ្វើ វិសោធនកម្មទៅលើ របាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីបោះផ្សាយនោះ អង្គភាពត្រូវនិយាយពីហេតុការណ៍នេះ។

១៨ ជាការសំខាន់ណាស់សម្រាប់អ្នកប្រើប្រាស់ ក្នុងការដឹងពីពេលវេលាដែល របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ពីព្រោះរបាយ-ការណ៍ហិរញ្ញវត្ថុ មិនបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ បន្ទាប់ពីកាលបរិច្ឆេទ នេះទេ ។

ការធ្វើបច្ចុប្បន្នកម្មការលាតត្រដាងពីលក្ខខណ្ឌនៅការិយបរិច្ឆេទរាយការណ៍

១៩ ប្រសិនបើអង្គភាពមួយទទួលបានព័ត៌មាន បន្ទាប់ពីការិយបរិច្ឆេទរាយ-ការណ៍ អំពីលក្ខខណ្ឌដែលបានកើតឡើងនៅចុងការិយបរិច្ឆេទរាយការណ៍ នោះអង្គភាពត្រូវធ្វើបច្ចុប្បន្នកម្មការលាតត្រដាងបង្ហាញ ដែលទាក់ទងនឹង លក្ខខណ្ឌទាំងនោះ ទៅតាមព័ត៌មានដែលទើបទទួលបានថ្មី ។

២០ ក្នុងករណីខ្លះ អង្គភាពមួយ ត្រូវការធ្វើបច្ចុប្បន្នកម្មការលាតត្រដាង នៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីឆ្លុះបញ្ចាំងពីព័ត៌មាន ដែលទទួលបាន បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ទោះបីជាព័ត៌មាននោះមានជះឥទ្ធិពល ដល់ទឹកប្រាក់ ដែលអង្គភាពទទួលស្គាល់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួនក៏ដោយ។ ឧទាហរណ៍មួយនៃតម្រូវការ ដើម្បីធ្វើបច្ចុប្បន្នកម្មការ លាតត្រដាងគឺនៅពេលភស្តុតាងកើតមានបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ អំពីបំណុលយថាហេតុ ដែលមានស្រាប់ នៅការិយបរិច្ឆេទរាយការណ៍។

បន្ថែមលើការពិចារណាថាតើ អង្គភាពគួរតែទទួលស្គាល់ ឬក៏ផ្លាស់ប្តូរ សំវិធានធនមួយ ដោយយោងទៅតាម ស.គ.អ. ៣៧ អង្គភាពធ្វើបច្ចុប្បន្នកម្ម ការលាតត្រដាងអំពីបំណុលយថាហេតុ ទៅតាមព័ត៌មានថ្មីនេះ ។

ព្រឹត្តិការណ៍មិនត្រូវធ្វើនិយ័តភាពបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

២១ ប្រសិនបើ ព្រឹត្តិការណ៍មិនត្រូវធ្វើនិយ័តភាព បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ មានទំហំជាសារវន្ត ការមិនលាតត្រដាងអាចជះឥទ្ធិពលដល់ការសម្រេចចិត្តសេដ្ឋកិច្ចដែលអ្នកប្រើប្រាស់ធ្វើការសំរេចចិត្តលើរបាយការណ៍ហិរញ្ញវត្ថុ។ ហេតុនេះ អង្គភាពមួយត្រូវលាតត្រដាងខ្នង់សារវន្តនីមួយៗ ខាងក្រោមនៃ ព្រឹត្តិការណ៍មិនធ្វើនិយ័តភាព បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍:

(ក) លក្ខណៈនៃព្រឹត្តិការណ៍

(ខ) ការប៉ាន់ស្មានពីផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុរបស់អង្គភាព ឬរបាយការណ៍ដែលថា ការប៉ាន់ស្មានបែបនេះ មិនអាចធ្វើឡើងបានទេ។

២២ ខាងក្រោមនេះ គឺជាឧទាហរណ៍ ស្តីពីព្រឹត្តិការណ៍មិនត្រូវធ្វើនិយ័តភាព បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ដែលជាទូទៅត្រូវលាតត្រដាងដូចខាងក្រោម ÷

(ក) ការបញ្ចូលអាជីវកម្មសំខាន់ៗ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ (ស.រ.ហ.អ. ៣ *ការរួមអាជីវកម្ម* តម្រូវឱ្យមានការលាតត្រដាងករណីបែបនេះ) ឬ ក៏ការបោះបង់ចោលនូវក្រុមហ៊ុនបុត្រសម្ព័ន្ធសំខាន់ៗ។

(ខ) ការប្រកាសពីផែនការបញ្ឈប់ប្រតិបត្តិការអាជីវកម្មមួយ។

(គ) ការទិញ និងការបោះបង់ចោលនូវទ្រព្យសកម្មសំខាន់ៗ ចំណាត់ថ្នាក់នៃទ្រព្យសកម្មថែរក្សាទុក សម្រាប់លក់ចេញ ដោយយោងតាម ស.រ.ហ.អ. ៥ ទ្រព្យសកម្មរយៈពេលវែងសម្រាប់លក់និងប្រតិបត្តិការមិនបន្ត ការបោះបង់ចោលនូវទ្រព្យសកម្មផ្សេងទៀត ឬ វិភាជន៍នូវទ្រព្យសកម្មសំខាន់ៗ ដោយរដ្ឋាភិបាល ។

(ឃ) ការខូចខាតរោងចក្រផលិតកម្មសំខាន់មួយ ដោយសារអគ្គីភ័យ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ។

(ង) ការប្រកាស ឬការចាប់ផ្តើមអនុវត្តនូវ ការកែប្រែរចនាសម្ព័ន្ធដ៏សំខាន់មួយ (សូមមើល ស.គ.អ. ៣៧) ។

(ច) ប្រតិបត្តិការបោះភាគហ៊ុនធម្មតាសំខាន់ៗ និងប្រតិបត្តិការបោះភាគហ៊ុន ធម្មតាដែលមានសក្តានុពល បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ (ស.គ.អ. ៣៣ ÷ ចំណេញក្នុង១សន្លឹកហ៊ុន តម្រូវឱ្យអង្គភាព លាតត្រដាងនូវការពិពណ៌នាមួយទាក់ទងដល់ប្រតិបត្តិការបែបនេះ។ ក្រៅពីពេលដែលប្រតិបត្តិការរបៀបនេះទាក់ ទិននឹងបញ្ហានៃការធ្វើមូលធនកម្ម ឬប្រាក់បន្ថែម ការបំបែកបំណ្ណ ភាគហ៊ុន ឬទិញត្រឡប់នូវបំណ្ណភាគហ៊ុនបំបែកទាំងអស់នេះ គឺ សុទ្ធសឹងតែត្រូវធ្វើនិយ័តភាពដោយយោងតាម ស.គ.អ. ៣៣) ។

(ឆ) ការប្រែប្រួលមិនធម្មតាដ៏ធំមួយ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ក្នុងតម្លៃទ្រព្យសកម្ម ឬក៏ ការប្រែប្រួលអត្រាប្តូរប្រាក់បរទេស។

(ជ) ការប្រែប្រួលអត្រាពន្ធ ឬច្បាប់ពន្ធដែលបានអនុម័ត ឬប្រកាសបន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ ដែលវាមានឥទ្ធិពលខ្លាំងក្លាទៅលើទ្រព្យសកម្ម និងបំណុលពន្ធបច្ចុប្បន្នពន្យា(មើល ស.គ.អ. ១២ ÷ *ពន្ធលើប្រាក់ចំណូល*) ។

(ឈ) ការដាក់បញ្ចូលទៅក្នុងការសន្យាដ៏សំខាន់មួយ ឬ ក៏បំណុលជាយថាហេតុ (ឧទាហរណ៍) ដោយការបោះផ្សាយនូវប័ណ្ណធានាដ៏សំខាន់ៗ និង

(ញ) ការចាប់ផ្តើមការប្តឹងមួយដ៏សំខាន់ដែលកើតឡើងក្រៅពីព្រឹត្តិការណ៍ ដែលបានកើតឡើងបន្ទាប់ ការិយបរិច្ឆេទរាយការណ៍ ។

កាលបរិច្ឆេទប្រសិទ្ធភាព

២៣ អង្គភាពមួយត្រូវប្រើស្តង់ដារនេះសម្រាប់កាលបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥។ ការអនុវត្តមុនការកំណត់ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើអង្គភាព ប្រើស្តង់ដារនេះសម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមមុនថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ អង្គភាពនោះត្រូវលាតត្រដាងពីហេតុការណ៍នោះ។

ការដកចេញ ស.គ.អ ១០ (បានកែប្រែឆ្នាំ ១៩៩៩)

២៤ ស្តង់ដានេះ ជំនួស ស.គ.អ ១០ *បន្ទាប់ពីកាលបរិច្ឆេទតារាងតុល្យការ (បានកែប្រែក្នុងឆ្នាំ ១៩៩៩) ។*

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ